# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**កំពង់ផែស្វយ័តភ្នំពេញ**

ថ្ងៃ សុក្រ ១រោច ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

លេខ ៥១០/២២.ក. ស. ភ.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០២២

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការពន្យារពេលក្នុងការចេញផ្សាយរបាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ ជាលើកទីពីរ របស់ កំពង់ផែស្វយ័តភ្នំពេញ**

**កំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.)** មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា យោងតាមលិខិតលេខ ២៤២២/២២ ន.ម.ក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ បានអនុញ្ញាតឱ្យ ក. ស. ភ. ពន្យារពេលក្នុងការផ្តល់ជូនរបាយការណ៍ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ ជូន ន.ម.ក យ៉ាងយូរត្រឹម**ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២២**។

ដោយឡែក រហូតមកដល់ពេលនេះ សវនករឯករាជ្យ BDO នៅតែត្រូវការចំណាយពេលវេលាបន្ថែម ដើម្បីពិនិត្យមើលឡើងវិញលើការចុះបញ្ជិការគណនេយ្យសម្រាប់ការជួលដីបន្ត (Sublease) របស់ ក. ស. ភ. ទៅឲ្យក្រុមហ៊ុនដែលជាដៃគូសហការ។ ដូចនេះ របាយការណ៍ ប្រចាំត្រីមាសទី៣ ឆ្នាំ២០២២ របស់ ក. ស. ភ. នឹងត្រូវបន្តពន្យារពេលជាលើកទីពីរក្នុងការចេញផ្សាយរហូតដល់ **ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២២** វិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជន ជ្រាបជាព័ត៌មាន។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្តាល: អគារលេខ ៦៤៩ គីវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៤២៧ ៨០២ Email: ppapmpwt@online.com.kh